## ទោសទណ្ឌ (sentencing)

ក្នុងច្បាប់ជាតិ គោលបំណងនៃការដាក់ទោស គឺដើម្បីធ្វើឲ្យរាងចាល (deterrence) ស្តានីតិសម្បទា (rehabilitation) ដាក់ទោសជនល្មើស (retribution) ។ សម្រាប់ព្រហ្មទណ្ឌអន្តរជាតិវិញ គោលបំណងនៃការដាក់ទោស មានលក្ខណៈទូលាយជាង ដូចជាដើម្បីកសាង សន្តិភាព ផ្សះផ្សាជាតិ និង លុបបំបាត់និទណ្ឌភាព (impunity)។

ដើម្បីសម្រេចទោស តុលាការនឹងពិនិត្យមើលកត្តាមួយចំនួនដូចជា ភាពធ្ងន់ធ្ងរនៃបទល្មើស ស្ថានភាពនៃបុគ្គលជាប់ពិរុទ្ធជាដើម។ ការដាក់ទោស ត្រូវផ្អែកតាមករណីរបស់ពិរុទ្ធជននីមួយៗ (Kayishema, ICTR-95-1-T, 1999, S. 3-4) ដោយពិចារណាស្ថានភាពទាំងអស់ រាប់បញ្ចូលទាំងស្ថានទម្ងន់ (aggravating) ស្ថានសម្រាល (mitigating circumstances) ដូចជា លទ្ធភាពនៃការស្តានីតិសម្បទា ការបំពានអំណាច ឋានៈនៃជនល្មើស វិធីសាស្ត្រប្រព្រឹត្តល្មើស បទបញ្ជាថៅហ្វាយនាយ ការបង្ខំ (duress) ភាពចាំបាច់ (necessity) វិប្បដិសារី ចរិត សុខភាព និងអាយុរបស់ពិរុទ្ធជន....។ កត្តាទាំងនេះ នៅមានច្រើនទៀត (non-exhaustive)។

តុលាការព្រហ្មទណ្ឌអន្តរជាតិ បានកំណត់ដំណាក់កាលពិចារណាទោស ដោយឡែកពី សវនការសម្រេចលើពិរុទ្ធភាព។ ទោសអាចត្រូវបានប្តឹងឧទ្ធរណ៍។ ក្នុងករណីមានកំហុសធ្ងន់ធ្ងរ (discernable error) តុលាការសាលាឧទ្ធរណ៍ អាចកែសម្រួលទោសបាន។ ម្ចាស់បណ្តឹងឧទ្ធរណ៍ មិនគ្រាន់តែបង្ហាញថាមានកំហុសទេ ថែមទាំងបង្ហាញថា កំហុសនោះ នាំឲ្យមានយុត្តិធម៌មិនប្រក្រតី (miscarriage of justice) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 509-510)។